00848761

E176/2/1/4/Corr-2

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/SC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E176/2/1/4 | 00847663-00847725 | 26-09-2012 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| ក្នុងកថាខណ្ឌ ៩១ |

| សេចក្ដីលម្អិតនៃការកែតម្រូវ៖ |
|---|
| ក្នុងកថាខណ្ឌ ៩១ ត្រង់ចំណុច(តាមទ្រឹស្ដី នីតិវិធីសង្ខេប រួមបញ្ចូលនូវការកំណត់អង្គហេតុនានា ដោយយោងតាមបទដ្ឋានហួសពីវិមតិសង្ស័យ)។ |

ស្នើដោយ៖ SC — ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ Theon — ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ — ហត្ថលេខា៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26/09/2012
ម៉ោង (Time/Heure): 10:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH Arun

រវាងតុល្យភាពនៃភវនីយភាព និងការបង្ហាញថាហួសពីវិមតិសង្ស័យ ដែលផ្អែកលើវិធានការ ឬទណ្ឌកម្មដែលមាន។

40. នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់នោះ អង្គជំនុំជម្រះសាលាដំបូង មានមូលហេតុអាចជឿជាក់ថា មានការជ្រៀតជ្រែក ប៉ុន្តែ បានបដិសេធមិនធ្វើការស៊ើបសួរបន្ថែម ដោយយល់ឃើញថាភ័ស្តុតាងមានមិនគ្រប់គ្រាន់ទៅវិញ[108]។ យើងយល់ឃើញថា វិធីសាស្ត្រនេះពុំមានលក្ខណៈសមស្របឡើយ។

41. ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការដោះស្រាយបញ្ហាដោយប្រើនីតិវិធីសង្ខេប ដូចការប្រមើលមើលនៅក្នុងវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង ត្រូវប្រើនីតិវិធីសាមញ្ញមួយសម្រាប់ធ្វើការសម្រេច។ វិធាននេះមិនបានអនុញ្ញាតឱ្យសម្រេចដោយសេរី ដោយផ្អែកតាមភស្តុតាងកម្រិតទាបនោះទេ។ តាមទ្រឹស្តី នីតិវិធីសង្ខេប បានរួមបញ្ចូលនូវការកំណត់អង្គហេតុនានាដោយយោងទៅតាមបទដ្ឋានហួសពីវិមតិសង្ស័យ។ ឧទាហរណ៍ អំពើដែលត្រូវបានដោះស្រាយដោយសមស្រប រួមមានអំពើដែលដឹងជាសាធារណៈ ដោយសារតែចរិតលក្ខណៈនៃអំពើទាំងនោះ អំពើដែលត្រូវបានថតនៅក្នុងវីដេអូរបស់តុលាការ អំពើដែលបានប្រព្រឹត្តឡើងតាមរយៈឯកសារយថាភូត ឬដោយមានការទទួលស្គាល់។

Deleted: មិនតម្រូវឱ្យធ្វើ

Deleted: ប្រើ

Deleted: ទេ

42. វិធាន ៣៥ នៃវិធានផ្ទៃក្នុងមានការរៀបរាប់លម្អិតតិចតួចទាក់ទិននឹងនីតិវិធីអនុលោមតាមអនុវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នីតិវិធីសម្រាប់បង្ហាញពីការទទួលខុសត្រូវ ជាបទល្មើសព្រហ្មទណ្ឌ ឬជាបទល្មើសរដ្ឋបាលក្តី គួរតែអនុវត្តតាមលក្ខខណ្ឌមូលដ្ឋាននៃភាពយុត្តិធម៌។ បទដ្ឋាននៃការបង្ហាញភ័ស្តុតាងសមស្រប គឺជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវនេះ។ បន្ថែមពីលើនេះ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ដោយផ្អែកតាមនីតិវិធីដែលមានចែងនៅក្នុងវិធាន ៧៧(ច) "អង្គជំនុំជម្រះ *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* អាចចាប់ផ្តើមដំណើរការនីតិវិធី ដោយត្រូវកោះហៅបុគ្គល ណាមួយឱ្យមកឆ្លើយចំពោះការចោទប្រកាន់ប្រឆាំងលើរូបគាត់ នៅពេលដែលអង្គជំនុំជម្រះមានហេតុផលជឿជាក់ថា គាត់បានប្រមាថតុលាការ" [109]។ "អង្គជំនុំជម្រះដែលជារដ្ឋអាជ្ញាផង និងចៅក្រមផង ដែលទាក់ទិននឹងបទចោទនៃការ

[108] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៣០-៣១។

[109] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Aleksovski* , IT-95-14/1-AR77, 'សាលដីកាលើបណ្តឹងសាទុក្ខរបស់ *AntoNobilo* ប្រឆាំងនឹងសំអាងហេតុស្តីពីការប្រមាថតុលាការ " អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ កថាខណ្ឌ៥៥។